ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN No : 391
Date: 20.09.10 Time: 10:25
For : GMAC

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ ១៨៦ កប/ប្រ.ក                                    រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០១០

# ប្រកាស

## ស្តីពី

## ការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០១១

### រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៥/៣៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ទៅជាគណៈកម្មការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ

-បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញ អនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញ អនុក្រឹត្យលេខ ១១០ អនក្រ/បក. ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១០ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១១ ។

## ស ម្រេ ច

**ប្រការ១.-** ថ្ងៃបុណ្យដែលត្រូវឈប់ ហើយមានប្រាក់ឈ្នួលនៅ **ឆ្នាំ២០១១** ត្រូវអនុញ្ញាតឱ្យកម្មករនិយោជិត នៃសហគ្រាសគ្រឹះស្ថានទាំងអស់ ដែលមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ បានឈប់សម្រាកការងារដោយមានប្រាក់ឈ្នួលតាមការកំណត់ ដូចខាងក្រោម :-

| | | |
|---|---|---|
| -ទិវាចូលឆ្នាំសកល | សម្រាក **០១** ថ្ងៃ | គឺថ្ងៃទី ០១ ខែ មករា |
| -ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | សម្រាក **០១** ថ្ងៃ | គឺថ្ងៃទី ០៧ ខែ មករា |
| -ពិធីបុណ្យមាឃបូជា | សម្រាក **០១** ថ្ងៃ | គឺថ្ងៃទី ១៨ ខែ កុម្ភៈ |
| -ទិវានារីអន្តរជាតិ | សម្រាក **០១** ថ្ងៃ | គឺថ្ងៃទី ០៨ ខែ មីនា |



V.

អាសយដ្ឋានអគារលេខ ៣ មហាវិថីសហព័ន្ធរុស្ស៊ី, សង្កាត់ទឹកល្អក់១, ខណ្ឌទួលគោក, ភ្នំពេញ ប្រអប់សំបុត្រ P.O Box 1506 ទូរស័ព្ទ: (៨៥៥-២៣) ៨៨៤-៣៧៥. Fax: ៨៨២-៧៦៩

-ពិធីចូលឆ្នាំថ្មី ប្រពៃណីជាតិ សម្រាក ០៣ ថ្ងៃ គឺថ្ងៃទី ១៤ - ១៥ និងថ្ងៃទី ១៦ ខែ មេសា

-ទិវាពលកម្មអន្តរជាតិ សម្រាក ០១ ថ្ងៃ គឺថ្ងៃទី ០២ ខែ ឧសភា ជំនួសថ្ងៃទី ០១ ខែ ឧសភា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សម្រាក ០៣ ថ្ងៃ គឺថ្ងៃទី ១៣ - ១៤ និងថ្ងៃទី ១៦ ខែ ឧសភា ជំនួសថ្ងៃទី ១៥ ខែ ឧសភា ដែលចំថ្ងៃអាទិត្យ

-ពិធីបុណ្យវិសាខបូជា សម្រាក ០១ ថ្ងៃ គឺថ្ងៃទី ១៧ ខែ ឧសភា

-ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល សម្រាក ០១ ថ្ងៃ គឺថ្ងៃទី ២១ ខែ ឧសភា

-ទិវាកុមារអន្តរជាតិ និងទិវាកុមារកម្ពុជា សម្រាក ០១ ថ្ងៃ គឺថ្ងៃទី ០១ ខែ មិថុនា

-ព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចព្រះមហាក្សត្រី **ព្រះវររាជមាតា នរោត្តម មុនិនាថ សីហនុ** សម្រាក ០១ ថ្ងៃ គឺថ្ងៃទី ១៨ ខែ មិថុនា

-ទិវាប្រកាសរដ្ឋធម្មនុញ្ញ សម្រាក ០១ ថ្ងៃ គឺថ្ងៃទី ២៤ ខែ កញ្ញា

-ពិធីបុណ្យភ្ជុំបិណ្ឌ សម្រាក ០៣ ថ្ងៃ គឺថ្ងៃទី ២៦ - ២៧ និងថ្ងៃទី ២៨ ខែ កញ្ញា

-ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះករុណា **ព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សម្រាក ០១ ថ្ងៃ គឺថ្ងៃទី ២៩ ខែ តុលា

-ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះវររាជបិតា **ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ** សម្រាក ០១ ថ្ងៃ គឺថ្ងៃទី ៣១ ខែ តុលា

-ពិធីបុណ្យឯករាជ្យជាតិ សម្រាក ០១ ថ្ងៃ គឺថ្ងៃទី ០៩ ខែ វិច្ឆិកា

-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក សម្រាក ០៣ ថ្ងៃ គឺថ្ងៃទី ០៩ - ១០ និងថ្ងៃទី ១១ ខែ វិច្ឆិកា

-ទិវាសិទ្ធិមនុស្សអន្តរជាតិ សម្រាក ០១ ថ្ងៃ គឺថ្ងៃទី ១០ ខែ ធ្នូ ។

**ប្រការ២.-** ក្រៅពីថ្ងៃបុណ្យដូចមានចែងក្នុងប្រការ១ ខាងលើ តាមគោលការណ៍ដែលមានចែងក្នុងមាត្រា ១៤៧ នៃច្បាប់ស្តីពីការងារ ត្រូវឱ្យឈប់នៅថ្ងៃអាទិត្យ សម្រាប់កម្មករនិយោជិតទាំងអស់ ។

**ប្រការ៣.-** ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ២០១ កប/ប្រ.ក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤.-** ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**វង សូត**

**<u>ចម្លងជូន:</u>**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
  ដើម្បីជូនជ្រាប
-គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី-ខេត្ត
-គ្រប់សមាគមនិយោជក
-គ្រប់សហព័ន្ធសហជីព
  ដើម្បីផ្សព្វផ្សាយ និងអនុវត្ត
-រាជកិច្ច
-កាលប្បវត្តិ-ឯកសារ